**For Nepal regional workshop**

## សម្រាប់សិក្ខាសាលាថ្នាក់តំបន់នៅប្រទេសណេប៉ាល់

## ឯកសារ ១.២. តើអ្វីជាពលកម្មកុមារក្នុងការងារតាមផ្ទះ ?

**១. តើអ្វីជាការងារតាមផ្ទះ ?** អនុសញ្ញា ILO លេខ ១៨៩ ស្តីពីការងារតាមផ្ទះ កំណត់និយមន័យ "ការងារតាមផ្ទះ" ជាការងារដែលធ្វើឡើងនៅក្នុងឬសម្រាប់គ្រួសារមួយឬគ្រួសារច្រើន។ "កម្មការការងារតាមផ្ទះ" មានន័យថា អ្នកដែលធ្វើការតាមផ្ទះនៅក្នុងទំនាក់ទំនងការងារ។ ការងារតាមផ្ទះ គ្របដណ្តប់ទៅលើកិច្ចការនិងសេវាកម្មជាច្រើនដែលអាចខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត។ វាអាចមានភាពខុសគ្នាអាស្រ័យទៅតាម អាយុ យេនឌ័រ សាវតាជនជាតិ និងឋានៈទេសន្តរប្រវេសន៍របស់កម្មករ ព្រមទាំងបរិបទវប្បធម៌និងសេដ្ឋកិច្ចដែលពួកគេធ្វើការ។ វាអាចរួមមាន ការសម្អាត, ការដាំស្ល, ការបោកគក់និងអ៊ុតសម្លៀកបំពាក់, ការមើលថែទាំកូនក្មេង មនុស្សចាស់ ឬមនុស្សពិការ, ការបើកបរ, ការយាមផ្ទះ ឬការថែសួន ជាដើម។ *ភាពខុសគ្នារវាងការងារតាមផ្ទះ និងការងារផ្សេងទៀតនោះ គឺថា កម្មករត្រូវបានគេជួលនិងត្រូវផ្តល់សេវាកម្ម សម្រាប់គ្រួសារអ្នកដទៃដែលមិនមែនជាគ្រួសាររបស់ខ្លួនឯង។*

**២. តើអ្នកណាជាកុមារ ?** អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ និងអនុសញ្ញា ILO ស្តីពីពលកម្មកុមារ (លេខ ១៣៨ និង ១៨២) បានកំណត់និយមន័យ កុមារ ជា "បុគ្គលដែលមានអាយុក្រោម១៨ឆ្នាំ លើកលែងតែមានការកំណត់ដោយច្បាប់នៃប្រទេសណាមួយអំពីយុវវ័យ"។ *នៅក្នុងប្រទេសភាគច្រើនបំផុត ដោយរួមទាំងក្នុងទ្វីបអាស៊ី/ប៉ាស៊ីហ្វិចដែរនោះ អាយុតាមផ្លូវច្បាប់ស្រាប់មនុស្សពេញវ័យគឺ១៨ឆ្នាំ* ។

**៣. តើការងារនៅក្នុងផ្ទះដែលកុមារធ្វើនៅក្នុងផ្ទះរបស់ពួកគេ រាប់ចូលជាការងារតាមផ្ទះរបស់កុមារឬទេ ?** ការងារនៅក្នុងផ្ទះ ដែលកុមារធ្វើនៅក្នុងផ្ទះខ្លួនឯង ក្នុងលក្ខខណ្ឌសមហេតុផលនិងក្រោមការមើលខុសត្រូវរបស់មនុស្សជិតស្និទ្ធជាមួយកុមារទាំងនោះ គឺជាចំណែកដ៏សំខាន់នៃជីវិតក្នុងគ្រួសារនិងនៃការលូតលាស់របស់កុមារ។ ប៉ុន្តែ *វាអាចមានស្ថានភាពស្រដៀងនឹងពលកម្មកុមារ ប្រសិនបើការងារនោះ រំខានដល់ការអប់រំរបស់កុមារ ឬច្រើនហួសហេតុ ឬធ្ងន់ធ្ងរហួសហេតុ។* កុមារដែលធ្វើការងារនៅក្នុងផ្ទះខ្លួនឯង និងការងារធ្វើការងារតាមផ្ទះ (ក្នុងផ្ទះរបស់និយោជក) អាចប្រហែលធ្វើការស្រដៀងគ្នា។ សម្រាប់ការងារធ្វើការងារក្នុងផ្ទះខ្លួនឯង វាមិនមានជាតុណាមួយជាការធ្វើការនោះទេ ដូច្នេះ យើងមិនគួរចាត់ទុកថាវាជាការងារតាមផ្ទះនោះទេ។ ក៏ប៉ុន្តែ នៅពេលដែលឪពុកម្តាយតម្រូវឲ្យកូនរបស់ខ្លួន ធ្វើការងារនៅក្នុងផ្ទះសម្រាប់គ្រួសារក្នុងលក្ខខណ្ឌមិនអាចទទួលយកបាន គេចាត់ទុកវាថាជាពលកម្មកុមារនៅក្នុងការងារតាមផ្ទះដែលត្រូវការលុបបំបាត់មិនឲ្យមានឡើយ។

**៤. តើអ្វីជាការងារតាមផ្ទះសម្រាប់កុមារ ?** ការងារតាមផ្ទះសម្រាប់កុមារ គឺជាពាក្យទូទៅសម្រាប់ *ការងារដែលកុមារធ្វើនៅក្នុងផ្ទះរបស់និយោជកណាមួយ។* បញ្ញត្តិទូទៅនេះ គ្របដណ្តប់ទៅលើស្ថានភាពដែលច្បាប់អនុញ្ញាត និងដែលច្បាប់មិនអនុញ្ញាត។ ស្ថានភាពដែលច្បាប់អនុញ្ញាត គឺជាការងារដែល៖

- គោរពតាមអាយុអប្បរមានតាមច្បាប់ សម្រាប់ប្រភេទនិងលក្ខខណ្ឌការងារដែលកុមារត្រូវធ្វើ
- មិនរំខានដល់ការអប់រំរបស់កុមារ និង
- មិនបង្កគ្រោះថ្នាក់ដល់សុខមាលភាពរាងកាយ ផ្លូវចិត្ត ឬសីលធម៌របស់កុមារ ដោយសារតែលក្ខណៈរបស់ការងារ ឬដោយសារតែលក្ខខណ្ឌអនុវត្តការងារនោះ។

**៥. តើអ្វីជាពលកម្មកុមារនៅក្នុងការងារតាមផ្ទះ ហើយតើនៅពេលណាដែលគេចាត់ទុកថាវាជា "ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ"?** ថាតើទម្រង់ជាក់លាក់ណាមួយនៃការងារតាមផ្ទះ អាចហៅថាជា "ពលកម្មកុមារ" បានឬមិនបាននោះ អាស្រ័យទៅលើ អាយុកុមារ ប្រភេទនិងចំនួនម៉ោងការងារ ព្រមទាំង លក្ខខណ្ឌផ្សេងៗទៀតដែលកុមារធ្វើការងារនោះ។

**ប្រអប់ទី១ តើអ្វីជាពលកម្មការងារក្នុងការងារតាមផ្ទះ?**

ពលកម្មការងារក្នុងការងារតាមផ្ទះ សំដៅទៅលើ *ស្ថានភាពដែលច្បាប់មិនអនុញ្ញាត* ចំពោះការងារដែលកុមារធ្វើ ហើយកុមារនោះ មានអាយុក្រោមអាយុអប្បបរមា ស្ថិតក្នុងលក្ខខណ្ឌមានគ្រោះថ្នាក់ ឬស្ថិតក្នុងស្ថានភាពដូចជាទាសករ។ កុមារដែលស្ថិតក្នុងស្ថានភាពពលកម្មកុមារក្នុងការងារតាមផ្ទះ ត្រូវបានគេដកហូតនូវ កុមារវ័យ សក្តានុពល និងសេចក្តីថ្លៃថ្នូរ។

- ពួកគេធ្វើការដែលច្បាប់មិនអនុញ្ញាត ដោយសារតែអាយុវ័យក្មេងរបស់ពួកគេ។
- សុខមាលភាពរាងកាយ ផ្លូវចិត្ត ឬសីលធម៌របស់ពួកគេ ស្ថិតក្នុងសភាពគ្រោះថ្នាក់ ដោយសារលក្ខណៈនៃការងារដែលពួកគេធ្វើ និងលក្ខខណ្ឌផ្សេងៗទៀតដែលកុមារធ្វើការងារនោះ
- ការងារនោះ រំខានដល់ការសិក្សារបស់កុមារ ដកហូតឱកាសក្នុងការទៅសាលារៀន តម្រូវឲ្យកុមារឈប់រៀនមុនអាយុ ឬតម្រូវឲ្យកុមារត្រូវទៅរៀនគួបផ្សំជាមួយនឹងត្រូវធ្វើការច្រើននិងធ្ងន់ធ្ងរហួសហេតុ។

**ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ**

មាត្រា៣ នៃអនុសញ្ញា ILO លេខ ១៨២ កំណត់និយមន័យ ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ ជា៖

ក) រាល់ទម្រង់ទាសភាព ឬការអនុវត្តស្រដៀងទាសភាព ដូចជា ការលក់ឬជួញដូរកុមារ កញ្ចះបំណុល និងពលកម្មដោយបង្ខំឬពលកម្មចាំបាច់ខានមិនបាន ដោយរាប់បញ្ចូលទាំង ការជ្រើសដោយបង្ខំឬដោយចាំបាច់ខានមិនបានទៅលើកុមារសម្រាប់ប្រើនៅក្នុងជម្លោះប្រដាប់អាវុធដែរ

ខ) ការប្រើប្រាស់ សញ្ជរកម្ម ឬការផ្តល់កុមារសម្រាប់ពេស្យាចារ្យ, សម្រាប់ការផលិតភាពយន្តអាសអាភាស ឬសម្រាប់ការសម្តែងបែបអាសអាភាស

គ) ការប្រើប្រាស់ សញ្ជរកម្ម ឬការផ្តល់កុមារសម្រាប់សកម្មភាពខុសច្បាប់ ជាពិសេសសម្រាប់ការផលិតនិងជួញដូរគ្រឿងញៀន ដូចមានកំណត់នៅក្នុងសន្ធិសញ្ញាអន្តរជាតិដែលជាប់ទាក់ទង

ឃ) ការងារដែលមានលក្ខណៈឬមានស្ថានភាពទំនងជាធ្វើឲ្យមានការខូចខាតដល់សុខភាព សុវត្ថិភាព ឬសីលធម៌របស់កុមារ នៅពេលដែលកុមារធ្វើការងារនោះ។ «(សម្គាល់៖ "ការងារដែលមានគ្រោះថ្នាក់")»

ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ រួមមានស្ថានភាពរបស់ណាម្នាក់ដែលត្រូវបានគេជួញដូរឲ្យទៅផ្តល់សេវាធ្វើការងារតាមផ្ទះ

- ជាទាសករ ឬក្នុងលក្ខខណ្ឌដូចទាសករ
- ដែលត្រូវគេបំពានផ្លូវភេទឬកេងប្រវ័ញ្ចផ្លូវភេទ ឬពាក់ព័ន្ធនឹងការងារដែលច្បាប់ជាតិកំណត់ថាជាការងារដែលមានគ្រោះថ្នាក់ ដោយពិចារណាទៅលើអនុសាសន៍លេខ ១៩០ របស់អង្គការ ILO ដែរ។

**រាល់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារធ្វើការតាមផ្ទះ គឺជាទម្រង់ដែលមិនអាចទទួលយកបាននិងត្រូវតែលុបបំបាត់ចោល។ កុមារទាំងឡាយ គួរត្រូវដកចេញពីស្ថានភាពបែបនេះ ហើយចំណុចនេះ ត្រូវចាត់ទុកជាចំណុចអាទិភាព។**"

ប្រភព៖ Helping hands or shackled lives? Understanding child domestic labour and responses to it, ILOIPeC, Geneva, 2004
http://www.ilo.org/ipecinfo/product/download.do?type=document&id=348.

**៦. ការណ៍ពិតនិងតួលេខមួយចំនួនអំពីការងារតាមផ្ទះសម្រាប់កុមារ** (**ប្រភព៖** Source: ILO-IPEC fact sheet. 2013, "Child domestic work: Global estimates 2012")

មានភស្តុតាងលើសពីគ្រប់គ្រាន់នៅជុំវិញពិភពលោក ដោយរាប់ទាំងអាស៊ី/ប៉ាស៊ីហ្វិកផងនោះ ថា *ពលកម្មកុមារក្នុងការងារតាមផ្ទះ មានសភាពរីកសាយភាពយ៉ាងទូលាយ។*

- កុមារចំនួន ១៧,២ លាននាក់ កំពុងធ្វើការងារដោយបានប្រាក់ឈ្នួលឬមិនបានប្រាក់ឈ្នួល នៅក្នុងផ្ទះរបស់ភាគីទីបី ឬនិយោជក
- ក្នុងចំណោមនេះ *កុមារ ១១,៥លាននាក់ ស្ថិតនៅក្នុងស្ថានភាពពលកម្មកុមារ*
- ក្នុងនោះ កុមារ ៣,៧លាននាក់កំពុងធ្វើការងារដែលមានគ្រោះថ្នាក់ (២១,៤% នៃកុមារធ្វើការតាមផ្ទះទាំងអស់)
- ៥,៧ លាននាក់ ដែលភាគច្រើនជាកុមារវ័យជំទង់ កំពុងធ្វើការងារដែលអនុញ្ញាតដោយច្បាប់ ប៉ុន្តែ ពួកគេត្រូវការទទួលបានការការពារពីការបំពាន និងត្រូវការទទួលបានការងារសមរម្យ
- បន្ថែមពីលើនេះ កុមារក្នុងចំនួនមួយដែលមិនអាចកំណត់បាន កំពុងធ្វើការងារតាមផ្ទះ ដោយសារតែពលកម្មដោយបង្ខំ និងការជួញដូរ

- ក្នុងចំណោមពលកម្មធ្វើការដោយបង្ខំចំនួន ២០,៩លាននាក់ មានកុមារអាយុ១៧ឆ្នាំចុះក្រោម ចំនួន ២៦% នៃជនរងគ្រោះដោយសារពលកម្មដោយបង្ខំ (ឬស្មើនឹងកុមារចំនួន ៥,៥លាននាក់)។ ទោះបីជា គេមិនដឹងចំនួនកុមារជាក់លាក់ដែលធ្វើការដោយបង្ខំនិងត្រូវគេជួញដូរឲ្យធ្វើការងារតាមផ្ទះក៏ដោយ ក៏ភស្តុតាងបានបង្ហាញអំពីចំនួនកុមារជាច្រើនដែលជាកញ្ចះបំណុល ជាជនរងគ្រោះដោយការជួញដូរ និងស្ថិតក្នុងស្ថានភាពដូចទាសករ។
- ៦៧,១% នៃកុមារធ្វើការងារតាមផ្ទះទាំងអស់ គឺជាកុមារី។ មានការប៉ាន់ប្រមាណថា កុមារីអាយុក្រោម១៦ ដែលកំពុងផ្តល់សេវាកម្មតាមផ្ទះ មានចំនួនច្រើនជាងនៅក្នុងវិស័យការងារណាៗទាំងអស់។
- ៦៥,១% នៃកុមារធ្វើការងារតាមផ្ទះទាំងអស់ មានអាយុក្រោម១៤ឆ្នាំ ក្នុងនោះរួមមាន ៧,៤% អាយុពី៥ ដល់១១ឆ្នាំ និង ៣,៨% អាយុពី១២ ដល់១៤ឆ្នាំ។

## ៧. លក្ខណៈពិសេសសាមញ្ញនៃការងារតាមផ្ទះរបស់កុមារ និងកុមារធ្វើការងារតាមផ្ទះនៅអាស៊ី/ប៉ាស៊ីហ្វិក

- អាយុកុមារធ្វើការងារតាមផ្ទះទំនងជាមានអាយុពី១២ឆ្នាំឡើងទៅ ទោះបីជាមានកុមារជាច្រើន ចាប់ផ្តើមធ្វើការនៅអាយុតិចជាងនេះក៏ដោយ
- កុមារីមានចំនួនភាគច្រើនបំផុត។ ពួកគេធ្វើការដែលជាធម្មតាចាត់ទុកថាជាចំណែកនៃការងារប្រចាំថ្ងៃរបស់មនុស្សស្រី ដូចជា មើលថែក្មេង បោសសម្អាត បោកអ៊ុតខោអាវ ដាំស្ល ដងទឹកនិងប្រេងមកផ្ទះ មើលថែសត្វចិញ្ចឹមរបស់គ្រួសារ ទៅទិញទំនិញ ដើរទៅនេះទៅនោះ មើលថែមនុស្សចាស់ ជាដើម។ ជួនកាល ពួកគេជួយរកស៊ីឬលក់ដូចតិចតួច។
- នៅពេលដែលគេជួលក្មេងប្រុសឲ្យធ្វើការ ជាធម្មតា គេច្រើនតែឲ្យធ្វើការក្រៅផ្ទះច្រើនជាង (ថែសួន បោសសម្អាតទីធ្លា លាងឡាន)
- កុមារជាច្រើននៅក្នុងប្រទេសបង់ក្លាដេស ប៉ាគីស្ថាន និងស្រីលង្កា ត្រូវគេយកមកធ្វើការជាអ្នកធ្វើការងារតាមផ្ទះ ដោយសារតែការជាប់ជំពាក់បំណុល។
- ភាពថប់បារម្ភនិងការឲ្យតម្លៃខ្លួនឯងទាប ដែលកើតឡើងទៅកុមារធ្វើការងារតាមផ្ទះ បណ្តាលមកពីស្ថានភាពរំលោភបំពាន ត្រូវបានគេរកឃើញថា ជាឧបសគ្គយ៉ាងសំខាន់ ក្នុងការពង្រឹងភាពអង់អាចដល់ពួកគេ
- ការមានឱកាសទទួលការអប់រំនិងការបន្តការសិក្សា គឺជារឿងដែលលំបាកបំផុតសម្រាប់កុមារធ្វើការងារតាមផ្ទះ។ សម្រាប់កុមារដែលនៅបន្តទៅសាលារៀនបាន ការងារបានរំខានជាប្រចាំទៅលើសមត្ថភាពក្នុងការធ្វើកិច្ចការសាលានិងរៀនមិនឲ្យទាន់គេ
- ជារឿយៗ សាលារៀនមិនបានដឹងអំពីតម្រូវការរបស់កុមារធ្វើការងារតាមផ្ទះទេ ដែលជាហេតុធ្វើឲ្យកុមារមានអារម្មណ៍ភិតភ័យនិងអៀនខ្មាស នៅចំពោះមុខមិត្តភក្តិរបស់ពួកគេ

- កុមារធ្វើការងារតាមផ្ទះក្នុងចំនួនច្រើនមែនទែន មកពីក្រុមជនជាតិភាគតិចនិងក្រុមកុលសម្ព័ន្ធ ឬមកពីវណ្ណៈឬឋានៈសង្គមទាប
- កិច្ចព្រងព្រៀងការងារលាយលក្ខណ៍អក្សរ នៅតែជារឿងចម្លែកយ៉ាងខ្លាំងដដែល
- កង្វះខាតសេរីភាពក្នុងការចាកចេញពីគ្រួសារដែលកុមារធ្វើការឲ្យនោះ គឺជារឿងធម្មតាគ្រប់កន្លែង។ ឧទាហរណ៍ ក្នុងប្រទេសឥណ្ឌា មានការរាយការណ៍ថា ជនរងគ្រោះនៃការជួញដូរដើម្បីការងារតាមផ្ទះរបស់កុមារ មានទំនាក់ទំនងសង្គមតិចតួចបំផុតឬគ្មានសោះ ក្រៅតែពីទំនាក់ទំនងក្នុងគ្រួសាររបស់និយោជកនោះ។
- កុមារជាច្រើន យល់ថាខ្លួនត្រូវបានបង្ខំឲ្យសម្របតាមភាសានិងវប្បធម៌របស់គ្រួសារដែលខ្លួនធ្វើការឲ្យ
- ក្នុងគ្រួសារដែលម្តាយជាអ្នកធ្វើការងារតាមផ្ទះ កូនរបស់ពួកគេ ភាគច្រើនទំនងក្លាយទៅជាកុមារធ្វើការតាមផ្ទះដែរ។

៨. **ហេតុអ្វីការងារតាមផ្ទះរបស់កុមារមានការលាក់បាំង និងពិបាកដោះស្រាយខ្លាំង?** ការងារតាមផ្ទះរបស់កុមារ ច្រើនតែត្រូវបានលាក់បាំង និងពិបាកក្នុងការដោះស្រាយ *ដោយសារតែ វាមានការតភ្ជាប់ជាមួយនឹងរបៀបផែនរស់នៅក្នុងសង្គមនិងវប្បធម៌។*

*កត្តាសង្គមនិងវប្បធម៌៖* ក្នុងប្រទេសជាច្រើន ការងារតាមផ្ទះរបស់កុមារ ត្រូវបានគេទទួលយកជាលក្ខណៈសង្គមនិងជាលក្ខណៈវប្បធម៌។ គេក៏ចាត់ទុកវាក្នុងលក្ខណៈវិជ្ជមានមួយថា ជាប្រភេទការងារដែលមានការពារ មានសុវត្ថិភាព និងសមរម្យ និងត្រូវបានគេចង់បានជាងទម្រង់ការងារផ្សេងៗទៀត ជាពិសេស សម្រាប់កុមារី។ ការងារតាមផ្ទះរបស់កុមារ មានភាពរីករាលដាល ដោយសារតែឥរិយាបថសង្គមដែលប្រកាន់ភ្ជាប់ជាយូរយារណាស់មកហើយ ទាក់ទងនឹងតួនាទីនិងការទទួលខុសត្រូវរបស់ស្ត្រី នៅក្នុងនិងនៅក្រៅគ្រួសារ។ ជាទូទៅ ការងារតាមផ្ទះ ត្រូវគេចាត់ទុកថាជាផ្នែកមួយនៃការ "រៀនសូត្រហ្វឹកហ្វឺន" របស់កុមារី សម្រាប់ពេលធំនិងរៀបអាពាហ៍ពិពាហ៍។

| **ប្រអប់ទី២៖ ទិសាលភាពយេនឌ័រ** | |
|---|---|
| គេជឿថា កុមារីច្រើនជាង ១០០លាននាក់ ចន្លោះអាយុពី ៥ ដល់ ១៧ឆ្នាំ កំពុងជាប់ពាក់ព័ន្ធនឹងពលកម្មកុមារនៅទូទាំងពិភពលោក។ ក្នុងចំណោមនេះ គេប៉ាន់ប្រមាណថា មានជាងពាក់កណ្តាល (៥៣លាននាក់) កំពុងធ្វើការមានគ្រោះថ្នាក់។ ការណ៍ពិតដែលគួរឲ្យភ្ញាក់ផ្អើលជាពិសេសនោះ គឺថា កុមារី គឺជាចំនួនសមាមាត្រដ៏ធំមួយនៃកុមារដែលកំពុងធ្វើការនៅក្នុងទម្រង់ពលកម្មកុមារដែលមានគ្រោះថ្នាក់បំផុត រួមទាំងការងារដោយបង្ខំ ការងារដោះបំណុល និងពេស្យាចារ។ | |

Handout 1.2 What is child labour in Domestic Work?

*យេនឌ័រ គឺជាកត្តាសំខាន់បំផុតនៅក្នុងការងារតាមផ្ទះរបស់កុមារ។* កុមារី ត្រូវគេរំពឹងជាធ្វើការតាមផ្ទះជាចម្បងឬតែមួយមុខគត់ នៅក្នុងវប្បធម៌ជាច្រើន ដូច្នេះ ការងារក្នុងគ្រួសារទាំងវ័យក្មេង ត្រូវគេចាត់ទុកថា "ជារឿងធម្មតា" សម្រាប់ពួកគេ។ ការងារតាមផ្ទះ ក៏ច្រើនតែត្រូវគេមើលឃើញថា មានតម្លៃជាង ផលដែលទទួលបានពីការអប់រំដែរ ជាពិសេស នៅក្នុងករណីដែលឪពុកម្តាយគណនា ថាតើពួកគេអាចបង់ថ្លៃសាលានិងការចំណាយផ្សេងៗទៀតដោយរបៀបណានិងសម្រាប់កូនមួយណានោះ។ ជាទូទៅ ឪពុកម្តាយឲ្យកូនប្រុសទៅរៀន ច្រើនជាងឲ្យកូនស្រី។ ជាងនេះទៀត សាលារៀនជាច្រើន ជាកន្លែងដេលគួរឲ្យភ័យខ្លាច់សម្រាប់កុមារី ដោយសារតែកុមារីមានហានិភ័យពីការយាយីរំខានផ្លូវភេទពីមិត្តរួមថ្នាក់និងពីគ្រូ ព្រមទាំងមិនសូវទទួលបានការយកចិត្តទុកដាក់ដោយសារតែបុរេនិច្ឆ័យនិងកម្មវិធីសិក្សាមិនល្អ។ ដូច្នេះ ដោយសារតែយេនឌ័រមួយមុខគត់នោះ បានធ្វើឲ្យកុមារីជាច្រើនត្រូវបានគេទុកចោលមិនឲ្យទៅសាលារៀន ឬត្រូវបោះបង់ការសិក្សា ហើយចុងក្រោយត្រូវធ្លាក់ក្នុងការងារដែលត្រូវគេកេងប្រវ័ញ្ច។ ក្នុងចំណោមកុមារមិនបានចូលសាលារៀនជាង ១១០លាននាក់នោះ មានចំនួនជិត ២ ភាគ ៣ ជាកុមារី។ ចំណុចនេះ ក៏ជាការពន្យល់ដែរថា ហេតុអ្វីបានជាស្ត្រីមានចំនួនស្មើរតែជិត ២ ភាគ ៣ ជាប្រជាជនមិនចេះអក្សរ។ នៅពេលដែលគ្រួសារបញ្ជូនកុមារីឲ្យទៅធ្វើការនៅក្នុងគ្រួសាររបស់អ្នកដទៃ កុមារីទាំងនោះនឹងស្ថិតនៅក្រោមការត្រួតត្រាទាំងស្រុងរបស់និយោជកឬសាច់ញាតិ ដែលប្រហែលជាមិនគិតអំពីឧត្តមប្រយោជន៍របស់កុមារីទាំងនោះនៅក្នុងចិត្តរបស់ពួកគេឡើយ។ ការដែលគ្មានប្រព័ន្ធណាមួយសម្រាប់គ្រប់គ្រងឬពង្រឹងការអនុវត្តសិទ្ធិរបស់កុមារទេនោះ កុមារីវ័យក្មេងៗដែលងាយរងគ្រោះទាំងនេះ អាចនឹងទទួលការការវាយដំនិងការធ្វើបាបដោយព្រៃផ្សៃ ក៏ដូចជាការរំលោភបំពានតាមពាក្យសម្តីនិងផ្លូវភេទផងដែរ។

ការទទួលរងការរំលោភបំពានជាប្រចាំបែបនេះ នឹងនាំឲ្យបាត់បង់ការឲ្យតម្លៃខ្លួនឯងជាក់ជាមិនខានឡើយ ដោយធ្វើការឲ្យកុមារីព្រមទទួលយកឋានៈតូចទាប និងមិនមានលទ្ធភាពក្នុងការជំនះនឹងស្ថានភាពឡើយ។

*ការយល់ដឹងថាការរើសអើងយេនឌ័រ គឺជាបុព្វហេតុចម្បងនៃពលកម្មកុមារធ្វើការតាមផ្ទះ មានសារៈសំខាន់ខ្លាំងណាស់ ក្នុងការការពារកម្មករជាកុមារ និងក្នុងការទប់ស្កាត់និងលុបបំបាត់ពលកម្មកុមារក្នុងការងារតាមផ្ទះ។* ដូច្នេះ ទស្សនៈយល់ឃើញអំពីការប្រឆាំងការរើសអើង ជាតម្រូវការចាំបាច់ក្នុងការអនុវត្តកំណែទម្រង់ច្បាប់ គោលនយោបាយ និងកម្មវិធីនានា និងក្នុងការប៉ាន់ប្រមាណវាយតម្លៃអំពីផលវិបាកផ្នែកសង្គម សេដ្ឋកិច្ច និងសុខភាពនៃការងារតាមផ្ទះរបស់កុមារ។

ប្រភព៖ Give girls a chance: tackling child labour, a key to the future, ILO-IPeC, Geneva, 2009, Give_girls_a_ chance_report_en_Web.pdf.; Beyond child labour: affirming rights, UNICef, March 2001, http://www. unicef.org/publications/files/pub_beyond_en.pdf.; de Silva-de-Alwis R., Legislative reforms on child domestic labour: a gender analysis, UNICef, New York, January 2007http://www.unicef.org/gender/ files/Leg_Reform_on_Child_Domestic_Labour(1).pdf.

*ភាពឯកោនៃការងារតាមផ្ទះ៖* ដោយសារតែការរៀបចំតម្រូវឲ្យធ្វើការដាច់ដោយឡែកពីគេឯងនិងតែឯងនោះ ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ អាចកើតឡើងកាន់តែងាយស្រួល ចំពោះការងារតាមផ្ទះ ជាស្ថានភាពការ

ងារដទៃទៀត ហើយធ្វើឲ្យអ្នកក្រៅ មិនបានសង្កេតឃើញ។ ដូច្នេះ កុមារដែលទទួលរងការរំលោភបំពានផ្លូវកាយ ផ្លូវអារម្មណ៍ និងផ្លូវភេទ និងការប្រឈមមុខនឹងលក្ខខណ្ឌការងារដែលមានគ្រោះថ្នាក់នោះ មិនអាចមានលទ្ធភាពក្នុងការស្វែងរកសំណង និង/ឬ ការការពារបានឡើយ។ ចំណុចនេះ ជាការពិតកាន់តែពិសេស សម្រាប់កុមារវ័យក្មេងដែលពឹងផ្អែកទាំងស្រុងទៅលើនិយោជក ដែលជា"ឪពុកម្តាយជំនួស" របស់ពួកគេ សម្រាប់រឿងរ៉ាវគ្រប់បែបយ៉ាងទាំងអស់នោះ។

*ការអនុវត្តតាមលំដាប់ឋានានុក្រមនៅក្នុងការងារតាមផ្ទះ៖* លំដាប់ឋានានុក្រមក្នុងសង្គម (ក្រុមមនុស្សដែលមានលំដាប់ថ្នាក់ខ្ពស់ទាបនៅក្នុងសង្គម) បានចាក់ឫសយ៉ាងជ្រៅនៅក្នុងការងារតាមផ្ទះ ដែលជាមុខរបរមួយកំណត់ឡើងតាមរយៈការបំពេញសេវាកម្មផ្ទាល់ខ្លួន ដល់មនុស្សផ្សេងទៀតតាមបញ្ជារបស់គេ។ អ្នកធ្វើការងារតាមផ្ទះភាគច្រើន ចេញមកពីគ្រួសារក្រីក្រ គឺជាវណ្ណៈ/ឋានៈ"ទាប" ជាក្រុមជនជាតិភាគតិចឬក្រុមកុលសម្ព័ន្ធ និង/ឬ ជាអ្នកមកពីតំបន់ជនបទ។ ពួកគេ ច្រើនតែមានការសិក្សាជាផ្លូវតិចតួចបំផុតឬគ្មានសោះ។ ជាទូទៅ និយោជករបស់ពួកគេ ចេញមកពីវណ្ណៈ/ឋានៈកណ្តាលឬខ្ពស់ និងមានការអប់រំផ្លូវការត្រឹមកម្រិតណាមួយ។ ទំនាក់ទំនងអំណាចគឺច្បាស់ណាស់ លម្អៀងទៅខាងនិយោជក។

និយោជកភាគច្រើនបំផុត នៅតែមិនទាន់ជឿប្រាកដក្នុងចិត្តថា អ្នកធ្វើការតាមផ្ទះឲ្យពួកគេ គឺជាកម្មករដែលមានសិទ្ធិដូចកម្មករផ្សេងទៀតនៅឡើយទេ។ តាមពិតទៅ នៅក្នុងគ្រប់ភាសាទាំងអស់ ពាក្យថា "អ្នកធ្វើការតាមផ្ទះ" កម្រត្រូវបានគេប្រើណាស់។ អ្នកធ្វើការតាមផ្ទះ ត្រូវគេហៅថា "ឈ្នួល" "អ្នកបម្រើ" "ក្មេងប្រុស" ឬ "អ្នកជួយក្នុងផ្ទះ" ឬត្រូវបានគេហៅ ដោយយោងតាមការងារចម្បងរបស់ពួកគេ ដូចជា "អ្នកបោកគក់" "អ្នកដាំស្ល/ចុងភៅ" "អ្នកមើលក្មេង" "អ្នកមើលថែ" "អ្នកសម្អាត" "អ្នកថែសួន" ឬ "សន្តិសុខ"។ ការងារដែលពួកគេធ្វើ ត្រូវបានចាត់ទុកថាជាការងារដែលគ្មានជំនាញ ឬមិនត្រូវការជំនាញច្រើន ហេតុដូច្នេះហើយ ត្រូវទទួលបានឋានៈទាប។

កុមារធ្វើការងារតាមផ្ទះ ស្ថិតនៅថ្នាក់ទាបបំផុតក្នុងលំដាប់ក្នុងសង្គម។ ដោយសារតែពួកគេនៅក្មេង ពួកគេធ្វើការមិនបានលទ្ធផលច្រើនដូចកម្មករពេញវ័យនោះ និយោជកមានលេសក្នុងការផ្តល់កម្រៃពលកម្មទាប ឬជួនកាលផ្តល់ឲ្យត្រឹមតែអាហារនិងជម្រកស្នាក់នៅតែប៉ុណ្ណោះ។ ជារឿយៗ និយោជកអះអាងថា ពួកគេចាត់ទុកកុមារធ្វើការងារតាមផ្ទះ ដូចជាកូនប្រុសឬកូនស្រីរបស់ពួកគេអញ្ចឹង។ ភស្តុតាងពីការស្រាវជ្រាវនិងសិក្សានានាក្នុងប្រទេសជាច្រើន បានបង្ហាញថា ការអះអាងនេះគ្មានមូលហេតុនោះទេ លើកលែងតែករណីតិចតួចបំផុត (សូមមើលក្នុងប្រអប់ទី៣ និងទី៤)។ កុមារ ជាពិសេសកុមារដែលក្មេងខ្លាំង សឹងតែគ្មានអ្វីទៅត្អូញត្អែរអំពីទង្វើដែលពួកគេបានទទួលពី "ឪពុកម្តាយជំនួស" របស់ពួកគេនោះទេ។ កុមារមួយចំនួនបែរជាមានអារម្មណ៍ថា ជំពាក់គុណនិយោជកដែលគ្រួសាររបស់កុមារបានផ្តល់ទំនុកចិត្តឲ្យទៅវិញទៀតផង។

**ប្រអប់ទី៣៖ ទំនាក់ទំនងអំណាចនៅក្នុងការងារតាមផ្ទះ**

"ដោយសារតែទំនាក់ទំនងអំណាចមានជាប់មកជាមួយនឹងពលកម្មការងារតាមផ្ទះស្រាប់មកហើយនោះ កុមារី អាចត្រូវបានមនុស្សប្រុសពេញវ័យរំលោភបំពាននៅក្នុងគ្រួសារឬដោយកុមារអាយុច្រើនជាងឬខ្លាំងជាង។ ពួកគេក៏ប្រហែលជាប្រឈមនឹងការរំលោភបំពានផ្លូវភេទពីអ្នកមកលេងគ្រួសារនោះ ឬដោយអ្នកដែលជួយធ្វើការផ្សេងទៀតនៅក្នុងផ្ទះនោះដែរ ...។ កុមារនៅក្នុងសេវាកម្មតាមផ្ទះ ក៏អាចទទួលរងការបំពានលើរាងកាយ អាចត្រូវគេវាយដំជាប្រព័ន្ធដើម្បីឲ្យកុមារនោះធ្វើតាមតែគេប្រាប់និងមិនតមាត់ ឬត្រូវគេវាយដំជាទារុណកម្មនៅពេលដែលគេឃើញធ្វើការយឺតយ៉ាវឬមិនព្រមសហការណ៍ ឬមានកំហុសអ្វីមួយក្នុងការងារ។ កុមារទាំងអស់អាចត្រូវគេដុតឬអាចធ្វើទារុណកម្ម ដោយមនុស្សធំពេញវ័យក្នុងគ្រួសារនោះ និងដោយកូនក្មេងនៅក្នុងគ្រួសារនោះដែលបានមើលឃើញនូវការប្រព្រឹត្តអំពើឃោរឃៅ ថាជាទំនាក់ទំនងដែលមានសុពលភាពទៅលើសមាជិក "តូចទាប" នៅក្នុងគ្រួសារ ឬដោយអ្នកជួយធ្វើការក្នុងផ្ទះផ្សេងទៀត ដែលព្យាយាមចង់ដាក់នូវឋានានុក្រមលំដាប់ថ្នាក់របស់ខ្លួន សូម្បីតែក្នុងចំណោមអ្នកដែលត្រូវគេកេងប្រវ័ញ្ចដូចគ្នា"។

ប្រភព៖ *Helping hands or shackled lives? Understanding child domestic labour and responses to it*, ILOIPeC, Geneva, 2004 http://www.ilo.org/ipecinfo/product/download.do?type=document&id=348.

៩. **ហេតុអ្វីបានជាកុមារ ពិសេសកុមារី ត្រូវបានរុញឬទាញឲ្យចូលទៅក្នុងការងារតាមផ្ទះ?** មានឫសគល់ជាច្រើននៃការងារតាមផ្ទះរបស់កុមារ ប៉ុន្តែ ជាទូទៅ យើងអាចញែកចេញពីគ្នារវាងកត្តា "រុញច្រាន និង ស្រូបទាញ"។ កត្តារុញច្រាន គឺជាបញ្ហាដែលនាំឲ្យកុមារធ្លាក់ចូលទៅក្នុងការងារតាមផ្ទះ រីឯកត្តាស្រូបទាញ គឺជាលក្ខខណ្ឌដែលធ្វើឲ្យការងារតាមផ្ទះរបស់កុមារ មើលទៅអាចទទួលយកបាន ឬអាចមានភាពកាន់តែទាក់ទាញជាដំណោះស្រាយចំពោះបញ្ហាមួយចំនួន។ ក្នុងចំណោមកត្តារុញច្រាន មានដូចជា៖

- ភាពក្រីក្រនិងការផាត់ចេញពីសង្គម (កង្វះ/ការបដិសេធការទទួលបានធនធាន សិទ្ធិ ឱកាស ទំនិញ និងសេវាកម្មនានា)
- កង្វះការអប់រំនិងឱកាសអប់រំ
- ការរើសអើងដោយផ្អែកទៅលើយេនឌ័រ (សូមមើលប្រអប់ទី២) ពូជាសាសន៍ ពណ៌សម្បុរ សាសនា ដើមកំណើតជាតិ ប្រភពសង្គម
- អំពើហិង្សាដែលកុមារទទួលរងនៅក្នុងផ្ទះរបស់ខ្លួន
- ការផ្លាស់ប្តូរលំនៅដ្ឋានដោយបង្ខំ (ដោយសារជម្លោះប្រដាប់អាវុធ ជម្លោះផ្ទៃក្នុង និងការបំពានសិទ្ធិមនុស្សជាទម្លាប់ ព្រមទាំង គ្រោះមហន្តរាយធម្មជាតិឬបង្កដោយមនុស្ស)
- ការធ្វើចំណាកស្រុកពីជនបទមកតំបន់ទីក្រុង និង
- ការបាត់បង់ឪពុកម្តាយ ដោយសារតែជម្លោះ និង/ឬ ជំងឺ។

ក្នុងចំណោមកត្តាស្រូបទាញ មានដូចជា៖

- ការជំពាក់បំណុល (ឬគេស្គាល់ថាជា ទាសភាពបំណុល ឬពលកម្មដោះបំណុល) គឺជាការសន្យារបស់បុគ្គលម្នាក់ក្នុងការផ្តល់ពលកម្មឬសេវាកម្មរបស់ខ្លួនឬរបស់កូនខ្លួន ទៅនិយោជក ជាទ្រព្យធានា សម្រាប់ការសងបំណុលឬសងកាតព្វកិច្ចផ្សេងទៀតត្រឡប់ទៅវិញ។
- ការកើនឡើងនៃវិសមភាពសង្គមនិងសេដ្ឋកិច្ច
- ការទទួលយកនិងការរំពឹងទុកផ្នែកសង្គមនិងវប្បធម៌៖ ការងារតាមផ្ទះ មាន"សុវត្ថិភាព" និងជាការងារសមរម្យសម្រាប់កុមារ ជាពិសេស កុមារី
- ការយល់ឃើញថា និយោជកគឺជាអ្នកជាប់សាច់ញាតិ ដូច្នេះ និយោជកនោះនឹងផ្តល់នូវបរិយាកាសមួយការពារដល់កុមារនោះ
- ការកើនឡើងនូវតម្រូវការមនុស្សស្រីមក"ជំនួស"ការងារក្នុងផ្ទះ ដើម្បីឲ្យពួកគេបានចូលទៅក្នុងទីផ្សារការងារ
- ត្រូវការកម្មករវ័យក្មេងកាន់តែច្រើនឡើង ដោយសារតែតម្លៃឈ្នួលទាប និងមានហានិភ័យទាប់សម្រាប់និយោជក៖ ការរៀបចំការងារឯកជននិងផ្ទាល់ខ្លួន កម្មករមិនរឹងរូស ងាយស្រួលកេងប្រវ័ញ្ច បញ្ឈប់ និងរកជំនួស
- ការភ័ន្តច្រឡំថាសេវាកម្មការងារតាមផ្ទះ ផ្តល់ឱកាសដល់កម្មករជាកុមារសម្រាប់ការអប់រំ
- សេចក្តីប្រាថ្នាផ្ទាល់របស់កុមារ ចង់មានអនាគតល្អប្រសើរជាងនេះ

**ប្រអប់ទី៤៖ "ដូចគ្រួសារតែមួយ"៖ ទំនាក់ទំនងស្រពិចស្រពិល**

"ទោះបីជាឪពុកម្តាយជាច្រើនដឹងថា កូនរបស់ខ្លួននឹងទៅធ្វើការងារឲ្យគេក៏ដោយ ក៏ឪពុកម្តាយច្រើនតែដាក់កូនខ្លួន នៅជាមួយគ្រួសារថ្មី មិនមែនជា "អ្នកធ្វើការ" ទេ តែជា "កូនស្រី" ឬ "កូនប្រុស"។ ភាពមិនផ្លូវការនៃការរៀបចំនេះ ត្រូវនឹងការចង់បានទាំងរបស់ឪពុកម្តាយនិងរបស់និយោជក គឺថា វាអនុញ្ញាតឲ្យឪពុកម្តាយបន្តធ្វើពុតថា កូនរបស់ខ្លួនត្រូវបានគេមើលថែ នៅក្នុងបរិយាកាសគ្រួសារមួយ ស្របគ្នាជាមួយនឹងការលើកទឹកចិត្តឲ្យនិយោជកជឿថា ពួកគេកំពុងតែជួយកុមារនិងក្រុមគ្រួសាររបស់កុមារនោះ។ ក៏ប៉ុន្តែ វាតែងដើរផ្ទុយនឹងផលប្រយោជន៍របស់កុមារ តាមរយៈការតុបតែងរៀបចំបែបកេងប្រវ័ញ្ច និងបិទបាំងអំពើហិង្សានិងការរំលោភបំពាន។ នៅក្នុងសង្គមមួយចំនួននៅអាស៊ី/ប៉ាស៊ីហ្វិក គំនិតដែលថានិយោជកជាអ្នកផ្តល់ប្រយោជន៍នោះ ត្រូវបានធ្វើឲ្យមានភាពស្របច្បាប់ តាមរយៈការពិពណ៌នាទំនាក់ទំនងនេះជា "ការសុំកូន" ដោយជនមិនស្គាល់ ឬ "ការចិញ្ចឹម" ដោយជនដែលជាប់ជាសាច់ញាតិ។ ចំណុចនេះ បានបង្កើតនូវការយល់ឃើញអំពីទំនាក់ទំនងសាច់ញាតិ

| |
|---|
| ដែលចេះមើលថែទាំគ្នា និងការគាំទ្រជាសហគមន៍ ក្នុងការចិញ្ចឹមកូន។ តាមការពិត ចំណុចនេះ បានលាក់បាំងនូវហានិភ័យនៃពលកម្មកុមារ ដែលបានកើតឡើងនៅក្នុងការងារតាមផ្ទះទៅវិញទេ”។<br><br>ប្រភព៖ *Tackling child labour and protecting young workers in domestic work: a resource manual*, ILOIPeC/Global March Against Child Labour, New Delhi, ILO & Global March, 2014. |
| |

**១០. តើលក្ខខណ្ឌការងារនិងស្ថានភាពរស់នៅរបស់កុមារនិងយុវជនក្នុងការងារតាមផ្ទះមានលក្ខណៈដូចម្តេចខ្លះ?**

ក្នុងរយៈប៉ុន្មានឆ្នាំថ្មីៗនេះ ការសិក្សាត្រូវបានធ្វើឡើងនៅក្នុងកន្លែងជាច្រើននៅក្នុងពិភពលោក ដោយរួមទាំងតំបន់អាស៊ី/ប៉ាស៊ីហ្វិចដែរ ស្តីពីលក្ខខណ្ឌការងារនិងស្ថានភាពរស់នៅរបស់កុមារនិងយុវជនក្នុងការងារតាមផ្ទះ។ ការសិក្សាទាំងនេះ បានបញ្ជាក់ច្បាស់ថា ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ មានភាពរីករាលដាលយ៉ាងខ្លាំងនៅក្នុងការងារតាមផ្ទះ៖

- កុមារធ្វើការច្រើនម៉ោង ពី១០ ទៅ១២ ម៉ោងក្នុងមួយថ្ងៃ
- កុមារច្រើនតែធ្វើការពី៦ ទៅ៧ថ្ងៃ ក្នុងមួយសប្តាហ៍
- កុមារមានពេលសម្រាកខ្លីៗ ភាគច្រើនសម្រាកហូបអាហារ
- កុមារមួយភាគធំ (៩១% ក្នុងប្រទេសឥណ្ឌា) មិនមានថ្ងៃសម្រាកពីការងារទេ
- ការវាយដំ មិនមែនជារឿងចម្លែកទេ (ឧទាហរណ៍ ៣៥% ក្នុងប្រទេសឥណ្ឌា)
- នៅក្នុងករណីភាគច្រើនបំផុត ប្រាក់ឈ្នួល មានចំនួនតិចតួចស្តួចស្តើង ហើយជួនកាលគ្មាប្រាក់ឈ្នួលទេ ឬប្រាក់ឈ្នួលត្រូវបានកាត់ទុក
- ការបែកចេញពីគ្រួសារនិងបងប្អូនបង្កើត គួបផ្សំជាមួយឱកាសតិចតួចបំផុតក្នុងការចងមិត្តនិងចូលរួមក្នុងសង្គម ត្រូវបានរកឃើញថាបានគំរាមកំហែងដល់សុវត្ថិភាពផ្លូវអារម្មណ៍ និងធ្វើឲ្យអារម្មណ៍ក័ន្តច្រឡំកាន់តែមានសភាពខ្លាំងឡើង ទៅលើកុមារធ្វើការងារតាមផ្ទះ
- មានចំណងតភ្ជាប់យ៉ាងច្បាស់រវាងកុមារក្នុងសេវាកម្មការងារតាមផ្ទះនិងការជួញដូរមនុស្ស (ដែលមនុស្សត្រូវបានភ្នាក់ងារណាមួយចាប់ខ្លួន ឬលួងលោម ហើយបន្ទាប់មកលក់ទៅឲ្យអ្នកទិញដើម្បីកេងប្រវ័ញ្ចពលកម្មឬផ្លូវភេទ)
- កុមារទទួលរងគ្រោះដោយសារអាហារូបត្ថម្ភមិនគ្រប់គ្រាន់ កង្វះភាពឯកជន និងកង្វះពេលវេលាទំនេរសម្រាប់កំសាន្ត ឬសម្រាប់មិត្តភាព
- កុមារមានសិទ្ធិទទួលបានការអប់រំតិចតួចឬគ្មានសិទ្ធិទាល់តែសោះ

**ប្រអប់ទី៥÷ សម្លេងកុមារធ្វើការតាមផ្ទះ**

"ខ្ញុំក្រោកពីដេកនៅម៉ោង៤ព្រឹក ... ដាំស្ល សម្អាត លាងចាន និងបោសសម្អាត។ នៅពេលកូនគេក្រោកពីដេក ខ្ញុំងូតទឹកឲ្យ។ នៅពេលកូនង៉ែតដេកលក់ ខ្ញុំជួយយាយងូតទឹកដោយសារតែគាត់ចាស់ណាស់ហើយ។ បន្ទាប់មក ខ្ញុំបង្ហើយការងារដាំស្ល និងមើលថែទាំកូនតូចៗ។ នៅពេលឪពុកម្តាយគេ ត្រឡប់មកពីធ្វើការវិញ ... ខ្ញុំអ៊ុតខោអាវ និងរៀបចំអាហារពេលល្ងាចឲ្យរួចជាស្រេច"។ កុមារធ្វើការងារតាមផ្ទះ មកពីប្រទេសឥណ្ឌូណេស៊ី។

"ខ្ញុំបានចាប់ផ្តើមធ្វើការនៅអាយុ១២ឆ្នាំ។ ចាប់តាំងពីពេលនោះមក ខ្ញុំមិនដែលបានជួបគ្រួសារខ្ញុំទេ។ សត្រូវធំបំផុតរបស់ខ្ញុំ គឺការនឹកផ្ទះ។ ម្តាយខ្ញុំបានជួបខ្ញុំ នៅពេលនិយោជករបស់ខ្ញុំប្រាប់គាត់ជាចុងក្រោយអំពីកន្លែងដែលខ្ញុំធ្វើការនៅក្នុងទីក្រុងម៉ានីល។ ពួកគេមិនអនុញ្ញាតឲ្យអ្នកណាមកជួបខ្ញុំទេ ពីព្រោះពួកគេតែងតែវ៉ៃខ្ញុំ។ ខ្ញុំតែងតែចង់និយាយប្រាប់ឪពុកម្តាយរបស់ខ្ញុំអំពីជីវិតដ៏លំបាករបស់ខ្ញុំ ប៉ុន្តែខ្ញុំគ្មានឱកាសបានប្រាប់គាត់ទេ"។ កុមារធ្វើការងារតាមផ្ទះ មកពីប្រទេសហ្វីលីពីន។

"ឪពុកខ្ញុំបានស្លាប់នៅពេលដែលខ្ញុំអាយុ១៣ឆ្នាំ។ ខ្ញុំធ្វើការនៅក្នុងស្រែរបស់ពូខ្ញុំ ដើម្បីជួយចិញ្ចឹមគ្រួសារ។ នៅពេលដែលគាត់ឈប់ឲ្យយើងធ្វើការងារនេះ ខ្ញុំត្រូវរកការងារនៅកន្លែងផ្សេងទៀត ជាពិសេស ចាប់តាំងពីម្តាយរបស់ខ្ញុំធ្លាក់ខ្លួនពិការដោយសារគ្រោះថ្នាក់ចរាចរណ៍។ ខ្ញុំបានជួបបុរសម្នាក់ដែលបាននិយាយថា គាត់អាចរកការងារឲ្យខ្ញុំធ្វើនៅក្នុងប្រទេសថៃ។ ចុងក្រោយ ខ្ញុំបានទៅធ្វើការជាអ្នកបម្រើតាមផ្ទះនៅក្នុងទីក្រុងបាងកក សម្អាតផ្ទះ បោកខោអាវ និងលាងចាន។ ថៅកែខ្ញុំជាបុរសចំណាស់ម្នាក់។ បើខ្ញុំងើយមើលឡើងលើ គាត់វ៉ៃខ្ញុំហើយ។ ប្រពន្ធគាត់ជាមនុស្សល្អនិងមានចិត្តល្អ។ ប្រពន្ធគាត់បានសួរខ្ញុំថាមានបញ្ហាអ្វី ប៉ុន្តែខ្ញុំមិនអាចប្រាប់បានទេ។ ខ្ញុំឃំរាល់យប់អស់រយៈពេល៣ខែ។ ខ្ញុំមិនបានទទួលប្រាក់ឈ្នួលអ្វីទេ ហើយចុងក្រោយ ខ្ញុំបានលួចរត់ចេញ។ ដោយមានការជួយពីប៉ូលីសថៃ ខ្ញុំបានទៅដល់មណ្ឌលស្នាក់នៅមួយ ដែលខ្ញុំអាចរៀនជំនាញថ្មីៗ មុនពេលត្រឡប់ទៅផ្ទះវិញ"។ --កុមារធ្វើការតាមផ្ទះមកពីប្រទេសឡាវ។

"អ្វីដែលឈឺចាប់បំផុតនោះ មិនមែនការដាក់ទណ្ឌលើរាងកាយឬតាមពាក្យសម្តីនោះទេ នោះគឺពួកគេមិនបានបង្ហាញនូវទឹកចិត្តឬការគោរពដល់ខ្ញុំសូម្បីតែបន្តិចណាទាល់តែសោះ ទោះបីជាខ្ញុំខំប្រឹងធ្វើការយ៉ាងណាក៏ដោយ។ ខ្ញុំមិនសប្បាយចិត្តជាខ្លាំង នៅពេលដែលខ្ញុំនាំកូនគេទៅសាលារៀនឬទៅលេងសួន ហើយខ្ញុំមិនអាចចូលរួមជាមួយបានដែរ"។ --កុមារធ្វើការតាមផ្ទះមកពីប្រទេសឥណ្ឌា។

ប្រភព៖ Jonathan Blagbrough, *They respect their animals more – voices of child domestic workers,* AntiSlavery International London, 2007.

គ្រោះថ្នាក់ដែលជាប់ទៅនឹងកុមារតាមផ្ទះរបស់កុមារ មានច្រើន ដែលជាហេតុធ្វើឲ្យប្រទេសមួយចំនួន បានអនុម័តច្បាប់និងបទប្បញ្ញត្តិជាតិ ដោយកំណត់អំពីលក្ខខណ្ឌថាតើការងារអ្វីខ្លះដែលកុមារអាយុក្រោម១៨ឆ្នាំ អាច

ធ្វើបាន។ ខាងក្រោមនេះ គឺជាគ្រោះថ្នាក់សាមញ្ញៗបំផុតដែលកុមារប្រឈមនៅក្នុងសេវាកម្មការងារតាមផ្ទះ ដែលកាន់តែមានភាពធ្ងន់ធ្ងរ នៅពេលដែលពួកគេរស់នៅក្នុងគ្រួសាររបស់និយោជកៈ

- ចំនួនថ្ងៃធ្វើការមានរយៈពេលយូរនិងមានការនឿយហត់ច្រើន ដេកមិនគ្រប់គ្រាន់
- ប្រើប្រាស់សារធាតុគីមីពុល
- លើករបស់ធ្ងន់ៗ រួមមាន ទឹក ប្រេង សម្ភារៈត្រូវបោកអ៊ុត និងក្មេងដទៃទៀត
- ធ្វើការជាមួយរបស់មានគ្រោះថ្នាក់ ដូចជា កាំបិត ពូថៅ និងឆ្នាំងក្ដៅ
- ប្រើប្រាស់/ដំណើរការឧបករណ៍ ដូចជា ជណ្ដើរ ម៉ាស៊ីនបូមធូលី ម៉ាស៊ីនក្រឡុក ម៉ាស៊ីនកំដៅម្ហូប ធុងហ្គាស និងម៉ាស៊ីនបោកខោអាវ
- អាហារនិងកន្លែងសម្រាក មិនគ្រប់គ្រាន់ ព្រមទាំង
- ការធ្វើទង្វើមើលងាយឬបន្ទាបបន្ថោក រួមមាន អំពើហិង្សារាងកាយ អំពើហិង្សាពាក្យសម្ដី និងការរំលោភបំពានផ្លូវភេទ

ការធ្វើការងារក្រោមស្ថានភាពទាំងនេះ មានផលប៉ះពាល់រយៈពេលយូរនៅលើសុខមាលភាពផ្លូវកាយ ផ្លូវចិត្ត និងផ្លូវសីលធម៌របស់កុមារ។ ការដាក់ឲ្យកុមារប្រឈមនឹងគ្រោះថ្នាក់ទាំងនេះ គឺជាបដិសេធមិនផ្ដល់សិទ្ធិជាមូលដ្ឋានដល់ពួកគេៈ ឲ្យទទួលបានការថែទាំ និងការការពារពីការខូចខាត, ការសម្រាកនិងការលេង, មានការទាក់ទងជាប្រចាំជាមយយឪពុកម្ដាយនិងមិត្តភក្ដិវ័យដំណាលគ្នា, មានសិទ្ធិទទួលបានការអប់រំ។

## ១១. ហេតុអ្វីបានជាការអប់រំ មានសារៈសំខាន់ខ្លាំង ក្នុងការលុបបំបាត់ពលកម្មកុមារនៅក្នុងការងារតាមផ្ទះ ?

"កុមារម្នាក់ គ្រូម្នាក់ សៀវភៅមួយក្បាល ប៊ិចមួយដើម អាចផ្លាស់ប្ដូរពិភពលោកបាន" នេះជាសម្ដីរបស់ម៉ាឡាឡា យូសាហ្វហ្សៃ ដែលជាសកម្មជនជនជាតិប៉ាគីស្ថានដើម្បីទាមទារការអប់រំសម្រាប់ស្ត្រីនិងនិងអ្នកទទួលបានពានរង្វាន់ណូបែលវ័យក្មេងជាងគេបំផុត (២០១៤)។

*ការទទួលបានការអប់រំសម្រាប់កុមារនិងការលុបបំបាត់ពលកម្មកុមារ មានការជាប់ទាក់ទងគ្នាយ៉ាងជិតស្និទ្ធ។* នៅពេលដែលការអប់រំ ជាកាតព្វកិច្ចខានមិនបាន មិនបង់កម្រៃ និងមានគុណភាពល្អ វាអាចជួយកាត់បន្ថយពលកម្មមានយ៉ាងធំធេង។ ក៏ប៉ុន្តែ ចំណុចនេះ មិនទាន់អាចសម្រេចបាននៅឡើយទេនៅក្នុងប្រទេសជាច្រើននៅអាស៊ី/ប៉ាស៊ីហ្វិក។ ការអប់រំរបស់កុមារ អាចជាបន្ទុកដ៏ធំមួយសម្រាប់គ្រួសារក្រីក្រ សូម្បីតែនៅក្នុងប្រទេសដែលការអប់រំជាមូលដ្ឋាន មិនចាំបាច់បង់កម្រៃអ្វីក៏ដោយ។ ឧទាហរណ៍ តាមច្បាប់ ការអប់រំមិនចាំបាច់បង់កម្រៃទេ ហើយជាកាតព្វកិច្ចខានមិនបាន នៅក្នុងប្រទេសបង់ក្លាដេស រហូតដល់ថ្នាក់ទីប្រាំ ប៉ុន្តែ កត្តាជាច្រើន បានរួមចំណែកធ្វើឲ្យកុមារមិនអាចបញ្ចប់កម្រិតបឋមសិក្សាបាន ដូចជា អាត្រាសមាមាត្រខ្ពស់រវាងសិស្ស-គ្រូ ម៉ោងសិក្សាខ្លីដែលមានរយៈពេលតែ

២ ទៅ ៣ ម៉ោងប៉ុណ្ណោះ ព្រមទាំងការចំណាយខ្ពស់ខ្លាំងសម្រាប់ថ្លៃគ្រូ សៀវភៅ ឯកសណ្ឋាន ការធ្វើដំណើរ និងអាហារ។ ប្រទេសជាច្រើននៅក្នុងតំបន់ ដូចជាប្រទេសហ្វីលីពីន ដែលច្បាប់ដាក់កំណត់អំពីការអប់រំមូលដោយមិនបង់កម្រៃក៏ដោយ ក៏ស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នានេះដែរ។ បន្ថែមពីលើនេះ ទីតាំងសាលារៀនដែលនៅឆ្ងាយមិនបានបង្កលក្ខណៈងាយស្រួលដល់សិស្សក្នុងតំបន់ជនបទទេ ជាពិសេស សិស្សដែលរៀននៅកម្រិតមធ្យមសិក្សា។ ដូច្នេះ គ្រួសារក្រីក្រជាច្រើន បញ្ជូនកូនរបស់ខ្លួន ជាពិសេសកូនស្រី ឲ្យទៅធ្វើការជាអ្នកធ្វើការតាមផ្ទះនៅក្នុងផ្ទះរបស់សាច់ញាតិឬអ្នកជទៃដែលមានទ្រព្យច្រើនជាងខ្លួន ដោយសង្ឃឹមថា កូនរបស់ខ្លួននឹងបានទទួលការអប់រំ។ ប៉ុន្តែ ពលកម្មកុមារ **គឺជា** ឧបសគ្គដ៏ចម្បងមួយចំពោះការអប់រំ។ កុមារដែលធ្វើការច្រើនម៉ោង ជារឿយៗក្នុងលក្ខខណ្ឌដែលមានគ្រោះថ្នាក់ ពិតជាមិនអាចលៃលកពេលទៅសាលារៀនទេ។ កាលណាកុមារធ្វើការកាន់តែច្រើនម៉ោង កុមារកាន់តែទទួលបានប្រយោជន៍តិចតួចពីការរៀនសូត្រ។ ជាងនេះទៀត ប្រព័ន្ធអប់រំភាគច្រើន មិនបានរៀបចំឲ្យមានរចនាសម្ព័ន្ធសម្រាប់ជួលសម្រួលដល់កុមារធ្វើការតាមផ្ទះដែលមានម៉ោងធ្វើការមិនទៀងទាត់នោះទេ។

ការទទួលបានការអប់រំ គឺជាសិទ្ធិមូលដ្ឋានមួយរបស់កុមារ ដែលមានសារៈសំខាន់ខ្លាំងសម្រាប់ការអភិវឌ្ឍន៍និងសុខមាលភាពជាទូទៅរបស់កុមារ។ ការអប់រំ បង្កើនជម្រើស ផ្តល់ក្តីសង្ឃឹមសម្រាប់អនាគត និងផ្តល់ការគេចចេញពីការងារតាមផ្ទះរយៈពេលវែង។ ការទៅសាលារៀនធ្វើឲ្យគេមើលឃើញកុមារ ផ្តល់ការការពារមួយចំនួន និងផ្តល់ផលប្រយោជន៍ផ្នែកសង្គមក្នុងទម្រង់ជាមិត្តភាព ជាសកម្មភាពសង្គម និងការគាំទ្រពីមនុស្សធំ។ សាលារៀនដើរតួនាទីសំខាន់បន្ថែមចំនួនពីរទៀត។ ទីមួយ តាមរយៈការតាមដានវត្តមាន គ្រូអាចកំណត់អត្តសញ្ញាណកម្មករកុមារ និងអាចអ្នកឃ្លាំមើលទៅលើករណីនៃការរំលោភបំពាននិងការកេងប្រវ័ញ្ច។ ទីពីរ ការផ្តល់អាហារដោយមិនបង់កម្រៃនៅតាមសាលារៀន បានបញ្ជាក់ច្បាស់ថាជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយក្នុងការកាត់បន្ថយពលកម្មកុមារ។ អាហារថ្ងៃត្រង់ដោយមិនបង់កម្រៃសម្រាប់កុមារ គឺជាការលើកទឹកចិត្តសម្រាប់ឪពុកម្តាយក្នុងការបញ្ជូនកូនទៅសាលារៀន ដោយសារតែវាបន្ថយការចំណាយថ្លៃអាហារសម្រាប់គ្រួសារក្រីក្រ។ នេះជាការអនុវត្តទូទៅមួយនៅក្នុងកម្មវិធីមួយចំនួន ដើម្បីកាត់បន្ថយពលកម្មកុមារនៅក្នុងទ្វីបអាមេរិចឡាទីន។ នៅក្នុងប្រទេសហ្វីលីពីន កម្មវិធី "ផ្ទេរប្រាក់មានលក្ខខណ្ឌ (ប៉ង់តាវីដ)" ដែលគាំទ្រថវិការដោយរដ្ឋាភិបាល ផ្តល់ការលើកទឹកចិត្តជាលុយ ដល់គ្រួសារក្រីក្រ ក្រោមលក្ខខណ្ឌថា កូនរបស់ពួកគេទៅរៀនទៀងទាត់។ ស្រដៀងគ្នានេះដែរ នៅក្នុងប្រទេសឥណ្ឌូណេស៊ី កម្មវិធី "គាំទ្រការលុបបំបាត់ពលកម្មកុមារ (PPA-PKH)" ដែលជាកម្មវិធីផ្ទេរប្រាក់មានលក្ខខណ្ឌតាមគ្រួសារ បានផ្តល់នូវផលវិជ្ជមានមួយក្នុងការរក្សាកុមារឲ្យនៅក្នុងសាលារៀន។

*ការវិនិយោគក្នុងការអប់រំ នៅតែមានកម្រិតទាបហួសហេតុនៅអាស៊ី/ប៉ាស៊ីហ្វិក* ជាពិសេសនៅក្នុងអាស៊ីខាងត្បូង។ ប្រទេសបង់ក្លាដេស ចំណាយតែ ២.៦%, ប្រទេសប៉ាគីស្ថាន ចំណាយតែ ២.៧% និងប្រទេសឥណ្ឌា ចំណាយតែ ៣.៣% នៃថវិកាចំណូលរបស់ជាតិទៅលើវិស័យអប់រំ។ ប្រទេសឥណ្ឌា មានកុមារ ៤៤៥លាននាក់, ប្រទេសបង់ក្លាដេសមានកុមារ ៦៤លាននាក់ និងប្រទេសប៉ាគីស្ថាន មានកុមារ ៧០លាននាក់។ ប្រទេសទាំងបីនេះជាប្រទេសដែលមានកុមារចំនួន ១/៣ នៃកុមារទូទាំងពិភពលោក។ ប្រទេសឥណ្ឌានិងប្រទេសប៉ាគីស្ថាន មានចំនួន

កុមារនៅក្រៅសាលារៀន ច្រើនជាងគេនៅក្នុងពិភពលោក។ ទាក់ទងនឹងការរើសអើងយ៉ាងរីករាលដាលទៅលើកុមារី នោះ វិធានការជាក់លាក់ក្នុងការកែលម្អការទទួលបានការអប់រំ ពិតជាមានសារសំខាន់ខ្លាំងក្រៃលែង។ *ការវិនិយោគក្នុងការអប់រំក្មេងស្រី មិនត្រឹមតែផ្តល់ប្រយោជន៍ដល់ការអភិវឌ្ឍន៍បុគ្គលប៉ុណ្ណោះទេ គឺវាថែមទាំងជាមធ្យោបាយមួយគាំទ្រដល់ការរីកចម្រើនសង្គមនិងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាទូទៅទៀតផង។*

**ប្រអប់ទី៦៖ ផលប្រយោជន៍នៃការអប់រំកុមារី**

*ការកាត់បន្ថយអាត្រាមានកូនរបស់ស្ត្រី៖* ស្ត្រីដែលទទួលបានការអប់រំក្នុងប្រព័ន្ធ ទំនងជាពន្យារការរៀបអាពាហ៍ពិពាហ៍និងការមានកូន ហើយកូនមានចំនួនតិចនិងមានសុខភាពល្អជាងស្ត្រីដែលមិនបានទទួលការអប់រំក្នុងប្រព័ន្ធ។

*បន្ថយអាត្រាមរណៈទារកនិងកុមារ៖* ស្ត្រីដែលទទួលបានការអប់រំក្នុងប្រព័ន្ធខ្លះៗ ទំនងជាស្វែងរកការថែទាំវេជ្ជសាស្ត្រច្រើន ស្វែងរកការធានាថាកូនរបស់ពួកគេមានប្រព័ន្ធការពាររាងកាយមាំទាំ មានការយល់ដឹងអំពីតម្រូវការជីវជាតិរបស់កូន និងទទួលយកការអនុវត្តអនាម័យល្អ។ ជាលទ្ធផល ទារករបស់ពួកគេ មានអាត្រារស់ខ្ពស់ និងទំនងជាមានសុខភាពល្អជាង និងលូតលាស់ល្អជាង។

*បន្ថយអាត្រាមរណៈមាតា៖* ស្ត្រីដែលទទួលបានការអប់រំក្នុងប្រព័ន្ធ ទំនងជាមានចំណេះដឹងផ្នែកថែទាំសុខភាពល្អប្រសើរជាង។ ពួកគេមិនសូវមានផ្ទៃពោះនៅវ័យក្មេងនោះទេ។ ពួកគេទំនងជាមានផ្ទៃពោះតិចជាង និងមានគម្លាតប្រសើរជាង ព្រមទាំងមានការស្វែងរកការថែទាំមុនសម្រាលនិងក្រោយសម្រាល។

*ការពារប្រឆាំងនឹងការឆ្លងមេរោគ/ជំងឺអេដស៍៖* ការអប់រំកុមារី គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតមួយ ក្នុងការកាត់បន្ថយភាពងាយរងគ្រោះរបស់កុមារី ចំពោះការឆ្លងមេរោគ/ជំងឺអេដស៍។

*បង្កើនអាត្រាចូលរួមក្នុងកម្លាំងពលកម្មរបស់ស្ត្រីនិងបង្កើនចំណូល៖* ការអប់រំបង្កើតសក្តានុពលចំណូលសម្រាប់អ្នករកចំណូល និងកែលម្អផលិតភាពសម្រាប់និយោជក។

*ការជួយដល់មនុស្សជំនាន់បន្ទាប់៖* ម្តាយមួយរូបដែលទទួលបានការអប់រំក្នុងប្រព័ន្ធពីរបីឆ្នាំ ទំនងជាបញ្ជូនកូនរបស់ខ្លួនទៅសាលារៀនខ្លាំង។

ប្រភព៖ Give girls a chance: tackling child labour, a key to the future, ILO-IPeC, Geneva, 2009, Give_ girls_a_chance_report_en_Web.pdf.